# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សណុំរឿង**

លេខ ១៣១/០០៣/២០០៧

ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៧

**សេចក្តីសម្រេច**

លេខ ០៩២/០០៣/២០០៧ កបធ.ច

ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជសារ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៧ របស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពមាត្រា៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា ធម្មនុញ្ញបានទទួលនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៧ វេលាម៉ោង១៤ និង៣០ នាទី ។

***ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍***

***ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ***

- យល់ឃើញថា ព្រះរាជសាររបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៧ បានធ្វើឡើងត្រឹមត្រូវតាមមាត្រា១៤១ថ្មី នៃរដ្ឋធម្មនុញ្ញនិង មាត្រា១៨ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។
- យល់ឃើញថា មាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋបានចែងថា ចំពោះបទឧក្រិដ្ឋ និងបទឧក្រិដ្ឋតម្រូវឱ្យធ្វើការ ចៅក្រមមិនត្រូវគិតពីស្ថានគ្រាប្រណីទោស ឬបន្ធូរបន្ថយទោសក្រោមអប្បបរមាឬព្យួរទោសបានឡើយ ។ ចំពោះបទមជ្ឈិមដែលមិនប៉ះពាល់ដល់របៀបរៀបរយសាធារណៈធ្ងន់ធ្ងរទេ អាចត្រូវព្យួរទោសទាំងមូល ឬមួយផ្នែកបាន ។ ក្នុងករណីនេះ ជនដែលបានប្រព្រឹត្តបទល្មើស មិនត្រូវទទួលរងទណ្ឌកម្មចប់ចុងចប់ដើមទេ ប្រសិនបើខ្លួនមិនបានប្រព្រឹត្តបទល្មើសមួយផ្សេងទៀតដែលមានចែងក្នុងបណ្តាមាត្រាមុនៗក្នុងរយៈពេល ៥ ឆ្នាំ ក្រោយពីការកាត់ទោសរបស់ខ្លួន ។
- យល់ឃើញថា មាត្រា ៨ នេះកែប្រែមាត្រា ៧០ នៃបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការច្បាប់ព្រហ្មទ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ពុំមានប៉ះពាល់ដល់សិទ្ធិ និងផល

ប្រយោជន៍កុមារឡើយ បទបញ្ញត្តិនៃមាត្រា ៨ នៃច្បាប់ស្តីពីស្លាងទម្ងន់ទោសនៃបទឧក្រិដ្ឋ ខាងលើនេះពុំមានអធម្មនុញ្ញភាពទេ ។

- យល់ឃើញថា ជាគោលការណ៍ ក្នុងការជំនុំជម្រះក្តី ចៅក្រមពុំមែនគ្រាន់តែផ្អែកទៅលើមាត្រា៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋតែមួយនេះទេដើម្បីផ្តន្ទាទោសលើឧក្រិដ្ឋជន ប៉ុន្តែចៅក្រមត្រូវផ្អែកលើ ច្បាប់ ។ ពាក្យថាច្បាប់ខាងលើនេះ មានន័យថា ច្បាប់ជាតិ រួមមានរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល ច្បាប់ទាំងឡាយដែលនៅជាធរមាន ហើយនិងច្បាប់អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាបានទទួល ស្គាល់រួចមកហើយ ជាពិសេសអនុសញ្ញាស្តីពីសិទ្ធិកុមារ។

**<u>សម្រេច</u>**

**មាត្រា ១០** -មាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/ រកម/ ០១០២/០០៤ ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ២០០២ ត្រូវបានប្រកាសថាស្របនឹងធម្មនុញ្ញ ។

**មាត្រា ២** -សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ សេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ាហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានីភ្នំពេញថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**